**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៤៩ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០៦៨ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃភ្នំព្រេច ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.០៦៨ (ប្រាំបួនពាន់ហុកសិបប្រាំបី ) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃភ្នំព្រេច ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគីរី ក្រោមល័ក្ខខ័ណ្ឌសម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកាដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៤៧៤ សជណ.ស្ចន ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ផែនទី ទីតាំងដីវិនិយោគអភិវឌ្ឍន៍លើដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន លីម រ៉ូយ៉ាល់ ជ័យ ស្តុក ( LIM ROYAL JOINT STOCK COMPANY LIMITED )
ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រស្រុកពេជ្រាដា និងស្រុកកោះញែក ខេត្តមណ្ឌលគិរី លើផ្ទៃដី ៩០៦៨ ហិកតា




ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ..១៤០..ក.ស.ក.ស.ក ..
ចុះថ្ងៃទី ..០៦........ ខែ ធ្នូ ឆ្នាំ ២០១២
ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
អនុរដ្ឋលេខាធិការ

ម៉ុ_ម៉ុតមិន្ទ

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ..៤៧៤... សជណ.ក្រ
ចុះថ្ងៃទី ..១៧.... ខែ ធ្នូ ឆ្នាំ ២០១២
ទីស្តីការគណៈរដ្ឋមន្ត្រី

ស្វាស់ លាស់




មាត្រដ្ឋាន 1:90,000
0 1 2 Kilometers
Indian_1960_UTM_Zone_48N

សញ្ញាសំគាល់
• ចំណុចនិយាមកា
ទីតាំងដីវិនិយោគ
ផ្លូវជាតិ
ផ្លូវលំ
ស្ទឹង, អូរ
ព្រំប្រទល់ដែនជម្រកសត្វព្រៃភ្នំព្រេច

| Id | N | X | Y |
|---|---|---|---|
| 1 | A | 691806 | 1416619 |
| 2 | B | 691760 | 1423072 |
| 3 | C | 695811 | 1424762 |
| 4 | D | 701485 | 1430381 |
| 5 | E | 704794 | 1424822 |
| 6 | F | 695252 | 1417769 |